# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១០៨៣ អគ.កយ/០៤

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

## ឯឧត្តម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីសំណើសុំព្រះរាជអាជ្ញា សហការបង្ក្រាបទល្មើសលួចបើកច្រកទូរស័ព្ទអន្តរជាតិ តាមប្រព័ន្ធអ៊ីនធឺណែតខុសច្បាប់ ។

**យោង:** -លិខិតលេខ ១៦០៦-បទរប ចុះថ្ងៃទី២៣-០៨-២០០៤ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

-លិខិតលេខ ០៧.០៤ តកនសត ចុះថ្ងៃទី០២-០៣-២០០៤ របស់តុលាការកំពូល ។

ខ្ញុំសូមជម្រាបឯកឧត្តមមត្តាជ្រាបថា ក្រងយុត្តិធម៌បានទទួលលិខិតដូចមានយោងខាងលើស្នើសុំព្រះរាជអាជ្ញាសហការ មានវិធានការណ៍រដ្ឋបាលជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការបង្ក្រាបបទល្មើសលួចបើកច្រកទូរស័ព្ទអន្តរជាតិ តាមប្រព័ន្ធអ៊ីនធឺណែតខុសច្បាប់ ។

ពាក់ព័ន្ធនឹងករណីនេះ ក្រសួងយុត្តិធម៌សូមផ្តល់ជាយោបល់ តាមនិតិវិធីនៃច្បាប់ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដូចខាងក្រោម ៖

១-បើក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានការសង្ស័យថាមានជនល្មើសលួចបើកច្រកទូរស័ព្ទអន្តរជាតិ តាមប្រព័ន្ធអ៊ីនធឺណែតខុសច្បាប់ អាចប្តឹងចូលទៅនគរបាលយុត្តិធម៌ ស្នើសុំដីកាឆែកឆេរពីព្រះរាជអាជ្ញាដើម្បីធ្វើការឆែកឆេររកភស្តុតាង ។

២-បើរកទៅឃើញថា មានការលួចបើកច្រកទូរស័ព្ទអន្តរជាតិ តាមប្រព័ន្ធអ៊ីនធឺណែតខុសច្បាប់មែនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អនុវត្តតាមចំណុច(៣) នៃលិខិតលេខ ០៧.០៤ តកនសត ចុះថ្ងៃទី០២-០៣-២០១៤ របស់តុលាការកំពូល ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាបតាមការគួរ ។

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៤

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

ចម្លងជូន

-តុលាការខេត្ត-ក្រុង

-អយ្យការអមតុលាការខេត្ត-ក្រុង

ដើម្បីអនុវត្ត